**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៩៩ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឲ្យប្រើកម្មវិធីកាត់បន្ថយ ឬលុបពន្ធនាំចូលរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន- អូស្ត្រាលី- ណូវែលហ្សេឡង់

---

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋាន

---

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១០/០១៦ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី -ណូវែលហ្សេឡង់
- បានឃើញលិខិតជូនដំណឹងរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ទៅគ្រប់ស្ថានទូតរដ្ឋជាសមាជិកអាស៊ាន ស្ថានទូតអូស្ត្រាលីប្រចាំទីក្រុងភ្នំពេញ និងស្ថានទូតណូវែលហ្សេឡង់ប្រចាំទីក្រុងបាងកក ស្តីពីការបញ្ចប់នីតិវិធីចាំបាច់ក្នុងស្រុកសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - អូស្ត្រាលី - ណូវែលហ្សេឡង់

## សម្រេច

**ប្រការ ១ :** ប្រកាសឲ្យប្រើកម្មវិធីកាត់បន្ថយ ឬលុបពន្ធនាំចូលរបស់ព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល ២០០៩-២០២៥ ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - អូស្ត្រាលី - ណូវែលហ្សេឡង់ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២ :** អត្រាពន្ធនាំចូល ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចអនុវត្តបាន ដរាបណាទំនិញត្រូវមានដើមកំណើត ស្របតាមបទប្បញ្ញត្តិនានានៃវិធានដើមកំណើត និងនីតិវិធីប្រតិបត្តិនៃការចេញវិញ្ញាបនបត្រដើមកំណើត។

**ប្រការ ៣ :** អ្នកនាំចូលត្រូវគោរពតាមបទបញ្ជានានារបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា។

**ប្រការ ៤ :** ប្រកាសនេះ ចូលជាធរមាន នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០

គាត ឈន់

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ ក្រសួង ស្ថាប័ន ខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន
  "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- ឯកសារ -កាលប្បវត្តិ